1-877-328-9677




# របៀបប្រើប័ណ្ណ EBT របស់លោកអ្នកដើម្បីទិញម្ហូបអាហារ

នៅមុនពេលលោកអ្នកទិញទំនិញ សូមឆែកមើលចំនួនប្រាក់ដែលនៅសល់ក្រោយពីការចំណាយដោយមើលបង្កាន់ដៃចុងក្រោយរបស់លោកអ្នក ទូរស័ព្ទទៅផ្នែកបំរើអតិថិជនតាមលេខឥតបង់ប្រាក់ 1-877-328-9677 ឬតាមប្រព័ន្ធអ៊ិនធឺណិត www.ebt.ca.gov ។ ចំនួនដែលនៅសល់នេះ គឺជាចំនួនច្រើនបំផុតដែលអាចចំណាយជាមួយប័ណ្ណរបស់លោកអ្នក។

**ជំហានទី1** លោកអ្នកនាំយកទំនិញរបស់លោកអ្នកទៅកាន់ជួរគិតប្រាក់ ។ អាស្រ័យទៅលើហាងទំនិញ លោកអ្នកអាចត្រូវបែងចែកទំនិញជាមួយដែលមានសិទ្ធិទិញដោយឡែកពីមុខរបស់ដែលលោកអ្នកមិនមានសិទ្ធិទិញ ។

**ជំហានទី2** ឆូតប័ណ្ណរបស់លោកអ្នកក្នុងម៉ាស៊ីនចំណុចលក់ទំនិញ (POS) ឬហុចប័ណ្ណ EBT របស់លោកអ្នកទៅឱ្យអ្នកគិតប្រាក់ ។

**ជំហានទី3** ចុចបញ្ចូលលេខសម្ងាត់ (PIN) បួនខ្ទង់របស់លោកអ្នកទៅលើបន្ទះលេខចុច ។ ម៉ាស៊ីននឹងបង្ហាញសញ្ញា **** ជាជំនួសលេខដែលលោកអ្នកចុច ។

**ជំហានទី4** សូមចុចពាក្យ "ENTER" ។

**ជំហានទី5** អ្នកគិតប្រាក់ចុចបញ្ចូលចំនួនតម្លៃទំនិញ ។ បើសិនជាចំនួនទឹកប្រាក់នោះត្រឹមត្រូវ លោកអ្នកត្រូវចុចពាក្យ "OK" ឬ ពាក្យ "YES" ។

**ជំហានទី6** លោកអ្នកនឹងទទួលសំណៅបង្កាន់ដៃបោះពុម្ពមួយច្បាប់បង្ហាញៈ

- ឈ្មោះនិងអាសយដ្ឋានហាងទំនិញ
- ចំនួនប្រាក់ដែលលោកអ្នកបានទិញ
- ចំនួនថ្មីនៅសល់បន្ទាប់ពីចំណាយនៃគណនីជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នក

**ជំហានទី7** សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកអាចដឹងចំនួននៅសល់ថ្មីបន្ទាប់ពីចំណាយ សំរាប់លោកអ្នកទៅទិញម្ហូបអាហារនៅពេលក្រោយ ។

គេមិនអាចគិតថ្លៃឈ្នួលសំរាប់ការប្រើជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នកឡើយ ។

# របៀបឆែកមើលចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយ នៃបណ្ណ EBT របស់លោកអ្នក

ចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយថ្មីរបស់លោកអ្នក ត្រូវបានបោះពុម្ពនៅលើបង្កាន់ដៃចុងក្រោយរបស់លោកអ្នក ។ **សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នកជានិច្ច** ។ បើសិនជាលោកអ្នកធ្វើបាត់បង្កាន់ដៃចុងក្រោយរបស់លោកអ្នក លោកអ្នកអាចទូរស័ព្ទទៅផ្នែកបំរើអតិថិជន សាកសួរហាងថាតើលោកអ្នកអាចឆែកមើលចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយនៅម៉ាស៊ីន POS ឬទេ ឬឆែកមើលចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយរបស់លោកអ្នកតាមប្រព័ន្ធអ៊ិនធឺណិត www.ebt.ca.gov ។

បើសិនជាលោកអ្នកបាត់បណ្ណ ឬក៏បណ្ណត្រូវគេលួច សូមទូរស័ព្ទឥតបង់ប្រាក់ទៅផ្នែកបំរើអតិថិជនជាបន្ទាន់តាមលេខ 1-877-328-9677 ហើយពួកគេនឹងជំរាបលោកអ្នកអំពីរបៀបទទួលបណ្ណថ្មី ។ បើសិនជាលោកអ្នកមិនបានរាយការណ៍ថាបណ្ណរបស់លោកអ្នកបានបាត់ឬចោរលួចទេ អ្នកណាម្នាក់អាចប្រើបណ្ណនិងចំណាយប្រាក់របស់លោកអ្នកទាំងអស់ ហើយជំនួយទាំងនេះនឹងមិនត្រូវបានផ្តល់ជូនលោកអ្នកវិញទេ ។

## សូមទូរស័ព្ទផ្នែកបំរើអតិថិជនតាមលេខឥតបង់ប្រាក់ បើសិនជា:

- លោកអ្នកបាត់បណ្ណ ឬត្រូវគេលួចបណ្ណរបស់លោកអ្នក ។
- បណ្ណរបស់លោកអ្នកខូច ប្រើការលែងកើត ។
- លោកអ្នកមានបំណងចង់ប្តូរលេខសម្ងាត់ PIN របស់លោកអ្នក ពីព្រោះលោកអ្នកភ្លេចលេខ ឬមាននរណាម្នាក់ដឹងលេខសម្ងាត់ PIN របស់លោកអ្នក ។ ការិយាល័យផ្តល់ជំនួយសាធារណៈរបស់លោកអ្នកអាចជួយប្តូរលេខសម្ងាត់ PIN របស់លោកអ្នកបាន ។
- លោកអ្នកមានបំណងចង់ដឹងអំពីចំនួនប្រាក់ដែលនៅសល់ក្នុងគណនីរបស់លោកអ្នក ។
- លោកអ្នកត្រូវបានគេគិតប្រាក់ថ្លៃទិញប៉ុន្តែលោកអ្នកមិនបានទទួលម្ហូបអាហារ ឬក៏គេគិតប្រាក់លោកអ្នកលើសពីចំនួនតម្លៃដែលលោកអ្នកបានទិញ ។
- លោកអ្នកមានសំណួរ ឬបញ្ហាផ្សេងទៀត ។

**ធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍**

**1-877-328-9677**

**TTY: 1-800-735-2929 (ប្រព័ន្ធទូរស័ព្ទបញ្ជូនបន្ត សំរាប់លោកអ្នកដែលមានភាពពិការក្នុងការស្តាប់និងការនិយាយ)**

សូមមើលតារាងនៅក្នុងកូនសៀវភៅណែនាំ EBT របស់លោកអ្នក និងសរសេរថ្ងៃដែលគេនឹងដាក់បញ្ចូលជំនួយទៅក្នុងគណនីរបស់លោកអ្នក :

________________________________________
(ថ្ងៃទី១ ទៅដល់ថ្ងៃទី១០នៃខែ)

STATE OF CALIFORNIA
HEALTH AND HUMAN SERVICES AGENCY
DEPARTMENT OF SOCIAL SERVICES

USDA គឺជាក្រសួងផ្តល់កិច្ចជួយនិងការងារស្មើៗគ្នា ។

PUB 390 (Cambodian) (5/09)